សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃពុធទី ៨មេសា ២០២០
លេចទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ៨ មេសា ២០២០

## *ក្រុមឆ្លើយតបរហ័សនឹងផ្តល់ការយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះប្រជាជន ត្រូវមើលថែទាំគ្នាទៅវិញទៅមក ចែករំលែកព័ត៌មាន អនុវត្តវិធានការការពារទាំងអស់គ្នា*

ថ្ងៃទី ៨ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន ៣០៧ នាក់ នៅក្នុងក្រុង Revere។

## ប្រភពទិន្នន័យសាធារណៈ:

ពេលនេះអ្នករស់នៅក្រុង Revere ទាំងអស់អាចចូលទៅមើលព័ត៌មាន និងការអាប់ដេតនានានៅលើ Revere.org។ ព័ត៌មានទាំងនោះរួមមានទាំងទិន្នន័យនៃចំនួនអ្នកឆ្លងប្រចាំថ្ងៃ ចំនួនអ្នកជាសះស្បើយ និងចំនួនអ្នកស្លាប់ជាដើម។ ពេលនេះ Revere.org បានបន្ថែមទំព័រថ្មីមួយ ដែលមានព័ត៌មានលម្អិតស្តីពីកម្មវិធីផ្តល់ជូនពិសេស ក៏ដូចជាម៉ោងធ្វើការរបស់ធនាគារនានា។

## ការយកចិត្តទុកដាក់មើលថែគ្នាទៅវិញទៅមក

ចាប់តាំងអីថ្ងៃ ១៨ មិនា មក ក្រុមការងារផ្សព្វផ្សាយរបស់សាលាក្រុងបានផ្តោតលើការគាំទ្រ និងជួយដល់ប្រជាជនដែលងាយរងគ្រោះនៅគ្រប់ទីកន្លែង រួមទាំងមនុស្សចាស់ យុវជន អ្នកមានចំណូលទាប អ្នកគ្មានផ្ទះ អ្នកមានលំនៅចល័ត និងប្រជាជនដែលគ្មានប័ណ្ណស្នាក់នៅ។ នៅក្នុង ៣ សប្តាហ៍ដំបូង ក្រុមការងារបានសម្រេចការងារមួយចំនួនដូចជា៖

- បញ្ចេញនូវបណ្តាញ របស់ក្រុមឆ្លើយតបរហ័ស ក្រុមបុគ្គលិករបស់សាលាក្រុង សមាគមន៍ និងអ្នកស្ម័គ្រចិត្ត ដើម្បីផ្តល់ជូននូវអាហារ និងជំនួយផ្សេងៗទៅលើបញ្ហាលុយកាក់ ផ្តល់របស់ប្រើប្រាស់ក្នុងផ្ទះ និងសេវាពិនិត្យសុខភាពជាដើម។
- ជ្រើសរើសបានអ្នកស្ម័គ្រចិត្តចំនួនជាង ២០០ នាក់ ដើម្បីជួយក្រុមការងារផ្តល់អាហារ និងជួយការងារនៅមណ្ឌលចាស់ជរា។

- ឆ្លើយតបទៅនឹងសំណួរតាមរយៈទូរសព្ទ ជាង ៣៥០ ខ្សែ ពីមនុស្សចាស់ និងការដឹកជញ្ជូនអាហារជិត ៣០០ កញ្ចប់ទៅកាន់កន្លែងស្នាក់នៅរបស់មនុស្សចាស់។
- ធ្វើការទូរសព្ទច្រើនជាង ១០០០០ ដងទៅកាន់មនុស្សចាស់ និងអ្នកនិយាយភាសាអេស្ប៉ាញ។
- ចែកចាយ Chromebooks ទៅមនុស្សចាស់ និងអ្នកដែលគ្មានលទ្ធភាពទិញផលិតផលបច្ចេកវិទ្យា។

## ការការពារប្រជាជនក្នុងក្រុង

ការចាត់ចែងច្បាប់ថ្មីពីក្រុមប្រឹក្សាសុខាភិបាល បានបញ្ជាក់ឲ្យរាល់អាជីវកម្មទាំងអស់ រៀបចំឲ្យបុគ្គលិកដែលធ្វើការមានការប្រុងប្រយ័ត្ន ដោយប្រើប្រាស់ឧបករណ៍ការពារសុវត្ថិភាពនានានៅពេលកំពុងបម្រើសេវាកម្ម។ អាជីវកម្មលក់ជាបញ្ជរ ដូចជាហាងនំប៉័ង និងកាហ្វេ ត្រូវប្តូរទៅជាការផ្តល់ជូនសេវាក្រៅទ្វារ ឬ Drive Through ឬ ដាក់បន្ថែមប្រព័ន្ធការពារសុវត្ថិភាព(ដូចជាប្រើកញ្ចក់ជារបាំង) បន្ថែមពីនោះ ត្រូវទទួលបានការអនុញ្ញាតិពីអធិការកិច្ចសិន។

សាលាក្រុងក៏បានណែនាំឲ្យប្រើប្រាស់សម្លៀកបំពាក់ធម្មតាមកបិទបាំងមុខ ដើម្បីកាត់បន្ថយការឆ្លង និងការពារអ្នកពីមនុស្សដែលមានផ្ទុកមេរោគដោយមិនដឹងខ្លួន។ អ្នកមិនចាំបាច់ប្រើម៉ាស់ពេទ្យ ឬម៉ាស N-95 នោះទេ ព្រោះវាជាវត្ថុចាំបាច់សម្រាប់ប្រើប្រាស់នៅមន្ទីរថែទាំសុខភាព ក៏ដូចជាអ្នកធ្វើការក្នុងវិស័យសុខាភិបាល។

## <u>សេវាកម្មរបស់ក្រុង</u>

**អាប់ដេត**

- លោកអភិបាលក្រុង Arrigo បានប្រកាសពីភាពអាសន្ននៃការឆ្លងនៅក្នុងក្រុង Revere កាលពីថ្ងៃ ១៩ មិន ២០២០។
- សេវាកម្មមូលដ្ឋានរបស់ទីក្រុងដែលផ្តល់ដោយប៉ូលីស Revere អគ្គីភ័យ, EMS មន្ទីរសាធារណការ និង Revere 311 នឹងបន្តផ្តល់ជូនប្រជាពលរដ្ឋ ដោយគ្មានការរំខានណាមួយឡើយ។
- អ្នករស់នៅ Revere គួរតែ Subscribe សេវាបញ្ជូនព័ត៌មានតាមអ៊ីម៉ែល និងសារជាអក្សរតាម revere.org/coronavirus ដើម្បីទទួលបានព័ត៌មានថ្មីៗ។
- Revere 311 នៅតែមានបុគ្គលិក ចាំឆ្លើយសំណួរ ឬដោះស្រាយកង្វល់ផ្សេងៗជូនប្រជាពលរដ្ឋ។ សូមទាក់ទងមកកាន់ 311 ឬ 781-286-8311 ឬអ៊ីម៉ែលមក Revere311@revere.org ។
- អាគារសាធារណៈក្នុងទីក្រុងទាំងអស់ត្រូវបានបិទ រហូតដល់មានការជូនដំណឹងបន្ថែម។ សេវាកម្មនានានៅតែផ្តល់ប្រជាជនតាមគេហទំព័រ Revere.org។
- រាល់សួនច្បារ និងសួនកុមារទាំងអស់ត្រូវបានបិទ រហូតដល់ថ្ងៃជូនដំណឹងបន្ថែម។
- សាលារដ្ឋនៅក្នុងក្រុង Revere នឹងមានចែកអាហារខ្ចប់ សម្រាប់សិស្សទាំងអស់ និងគ្រួសារ។ អាហារពេលព្រឹក និងថ្ងៃត្រង់ នឹងចែកជូនដល់កុមារដែលត្រូវការពីចន្ទ ដល់សុក្រ ពីម៉ោង ១០ ដល់ ១១ ព្រឹក និងម៉ោង ១១ ដល់១ ថ្ងៃត្រង់។

- អ្នកអាចស្វែងរកបណ្តាញផ្តល់ជំនួយទៅមកនៅលើ Revere.org ។ នៅទីនោះ អ្នកអាចរកបានជំនួយយ៉ាងទូលំទូលាយ ប្ញូករួមទាំងផ្នែកចំណីអាហារ សេវាថែទាំងសុខភាព សេវាធ្វើដំណើរ សិទ្ធជ្រកកោន និងសេវាផ្សេងៗទៀត។ ព័តិមានទាក់ទងនឹងសេវាទាំងនេះ នឹងមានការអាប់ដេតជារៀងរាល់ថ្ងៃនៅម៉ោង ៤ ល្ងាច។
- ទីក្រុង Revere បានបង្កើត ទំព័រ មួយ ដែលបង្ហាញព័តិមានពីដំណោះស្រាយ និងជំនួយទៅដល់អ្នកដែលបានរងផលប៉ះពាល់ ដូចជាអាជីវកម្មខ្នាតតូច នយោជក អាជីវកម្មមិនយកប្រាក់ចំណេញ និងកម្មករ។ ទំព័រនេះនឹងមានការអាប់ដេតជាប្រចាំថ្ងៃ រាល់ពេលដែលអ្វីៗមានការប្រែប្រួល។
- ក្រុមស្ម័គ្រចិត្ត volunteer database នឹងបើករាល់ថ្ងៃសុក្រ សម្រាប់អ្នកដែលចង់រកកម្មី ឬជំនួយក្នុងរយៈពេលច្រើនសប្តាហ៍ខាងមុខ។ អ្នកដែលបានចុះឈ្មោះធ្វើជាអ្នកស្ម័គ្រចិត្តរួច នឹងមានក្រុមការងារទាក់ទងទៅឆាប់ៗក្រោយបំពេញឯកសារគ្រប់គ្រាន់។